## ២ . សេចក្តីសំរេច

ភ្នំពេញ , ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ១៣ សសរ ស្តីពីការបរង្កើត លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវិនិយោគ

* * *

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា របស់ សម្តេចព្រះឧបយុវរាជនរោត្តម សីហនុប្រមុខរដ្ឋនៃ កម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិ វិនិយោគលេខ ០៧ សសរ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ និង សេចក្តីសំរេចលេខ ១០ សសរ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣
- តាមសំណើរបស់គណៈកម្មាធិការជាតិវិនិយោគ

## សំរេច

**ប្រការ ១ :** បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវិនិយោគហៅកាត់ថា " លេខាធិការដ្ឋាន គ ជ វ " ដែលមានទីតាំងនៅ ក្រសួងផែនការ ក្រោមការគ្រប់គ្រង នៃ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងផែនការ ។ ឯកឧត្តមឡាយ ព្រះហស្ត អនុរដ្ឋមន្ត្រី ក្រសួងផែនការ នឹង ទទួលការគ្រប់គ្រងនេះ ជំនួសមុខអោយ រដ្ឋមន្ត្រីក្រសួងផែនការ ។

**ប្រការ ២ :** សមាសភាពគណៈដឹកនាំ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការវិនិយោគមានដូចខាងក្រោម ÷

១ - លោក អ៊ុក ចាយ តំណាងក្រសួងផែនការ ជាលេខាធិការប្រតិបត្តិ
២ - លោក សា វ៉ាក់ខាន់ អ្នកការពារការណ៍របស់គណៈកម្មាធិការជាតិវិនិយោគ
៣ - លោក អ៊ុង ទាសិាម អ្នកការពារការណ៍របស់គណៈកម្មាធិការជាតិវិនិយោគ
៤ - លោក សយ សុខា តំណាងក្រសួងពាណិជ្ជកម្ម
៥ - លោក ឡាញ់ វណ្ណៈ តំណាងក្រសួងហិរញ្ញវត្ថុ
៦ - លោក ប៉ាន់ ប៊ុនធឿន តំណាងក្រសួងហិរញ្ញវត្ថុ
៧ - លោក ឯម ឃិនវៈ

៨ - លោក សៀង តឹមហាន

**ប្រការ ៣ :** លេខាធិការដ្ឋាន នៃ គណៈកម្មាធិការជាតិវិនិយោគ ជាជំនួយការអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិវិនិយោគ ហើយមានភារកិច្ចសំខាន់ៗដូចខាងក្រោម :

១ - រៀបចំចងក្រងឯកសារដែលបានប្រកាសផ្សាយទាំងឡាយ ដូចជាច្បាប់ បទបញ្ញត្តិ និង សេចក្ដីជូនដំណឹងផ្សេងៗ ដែលទាក់ទងនិង ការងារវិនិយោគនៅកម្ពុជា ដើម្បីផ្សព្វផ្សាយដល់អ្នកវិនិយោគជាតិ និងបរទេស ។

២ - ផ្ដល់ពត៌មាន និង បង្កលក្ខណៈងាយស្រួលដល់អ្នកវិនិយោគអំពីវិស័យផ្សេងៗ ដែលអាចវិនិយោគអំពីអង្គភាព កម្ពុជា ដែលត្រូវធ្វើការទំនាក់ទំនង អំពីរបៀបរបប ដែលអ្នកវិនិយោគត្រូវបំពេញ និង អំពីពត៌មានចាំបាច់ផ្សេង ៗ ។

៣ - បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់អ្នកវិនិយោគដោយមានរបៀបរបប ការងារតាមប្រព័ន្ធ " ច្រកចេញចូលតែមួយ " ព្រមទាំងធ្វើការសំរបសំរួលរវាង អ្នកវិនិយោគ និង ស្ថាប័នមានសមត្ថកិច្ច និង ពន្ធព័ន្ធនានារបស់ កម្ពុជា ។

៤ - ទទួលពាក្យសុំវិនិយោគដោយមានឯកសារ ចាំបាច់ទាំងឡាយភ្ជាប់ជាមួយអោយបានគ្រប់គ្រាន់ ដើម្បីសំរេច បានសមិទ្ធិគំរោងការងារគឺ :

ក / ការសិក្សាអំពីសមិទ្ធិលទ្ធភាពជាបឋមដោយមានរបាយការណ៍សេដ្ឋកិច្ច បច្ចេកទេស ក្នុងនោះត្រូវ បញ្ជាក់អោយបានច្បាស់លាស់នូវ :

- កម្មវិធីហិរញ្ញប្បទាន
- តំលៃទូទាត់បច្ចុប្បន្និយកម្ម
- អត្រាចំណេញជាសារវន្ត
- រយៈពេលនៃការវិនិយោគ
- បញ្ជីសំភារៈបរិក្ខារដែលត្រូវនាំចូល
- តំលៃដែលសង្គមជាតិត្រូវទទួល
- ការការពារបរិដ្ឋាន

ខ / ស្ថានភាពហិរញ្ញវត្ថុរបស់ម្ចាស់ពាក្យសុំ និង ឯកសារទាំងឡាយដែលទាក់ទងនឹងសកម្មភាពអតីតកាល នៃក្រុមហ៊ុន

គ / បញ្ជីការងារដែលអ្នកស្នើសុំបានអនុវត្តកន្លងមក

៥ - [illegible]

ពាក្យសុំ ។

៦ - ពិនិត្យ និង សិក្សាគំរោងវិនិយោគទាំងអស់ ហើយផ្តល់មតិជូនគណៈកម្មាធិការជាតិវិនិយោគ ពិនិត្យនិងសំរេច ។

៧ - ទទួលបន្ទុកចុះបញ្ជីលក្ខន្តិកៈ និង លិខិត អនុញ្ញាតអោយវិនិយោគ ។

៨ - រៀបចំការប្រជុំរបស់គណៈកម្មាធិការជាតិវិនិយោគ ព្រមទាំងធ្វើកំណត់ហេតុរបស់អង្គប្រជុំ ។

៩ - សហការជាមួយស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីតាមដានត្រួតពិនិត្យការអនុវត្តន៍ សកម្មភាព ការងារទាំងអស់របស់អ្នកវិនិយោគ ហើយបូកសរុបរាយការណ៍ជូនគណៈកម្មាធិការជាតិវិនិយោគ ដោយលើកអំពីវិធានការចាំបាច់ផ្សេងៗ ក្នុងករណីមានការប្រព្រឹត្តមិនត្រឹមត្រូវ ។

១០ - ធ្វើការសិក្សាអំពីគោលនយោបាយ និងបទបញ្ញត្តិដែលចាំបាច់ សំរាប់ការងារវិនិយោគ ហើយលើកជា សំណើជូនគណៈកម្មាធិការជាតិវិនិយោគ ពិនិត្យនិង សំរេច ។

១១ - គ្រប់គ្រង និង ថែរក្សារាល់ឯកសារទាំងឡាយដែលទាក់ទងនឹងការងារវិនិយោគ ។

ប្រការ ៤ : ក្នុងការអនុវត្តភារកិច្ចទាំងនេះ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិវិនិយោគ អាចអញ្ជើញម្ចាស់ពាក្យសុំមកបំភ្លឺ បន្ថែមអំពីគំរោងវិនិយោគរបស់ខ្លួន និង អាចអញ្ជើញអ្នកឯកទេស ឬ តំណាងរបស់ស្ថាប័ននានាមកពិគ្រោះពិភាក្សា និង ផ្តល់យោបល់ ។

ប្រការ ៥ : ក្នុងករណីចាំបាច់ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវិនិយោគ អាចបង្កើតការិយាល័យ និង ផ្នែកផ្សេងៗ នា ពេលខាងមុខ ។

ប្រការ ៦ : លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវិនិយោគ ត្រូវរៀបចំគំរោងថវិកា សំរាប់ចំណាយដោយឡែក ដើម្បីបំរើ ការងាររបស់គណៈកម្មាធិការជាតិវិនិយោគ ។

ប្រការ ៧ : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយបានទទួលលទ្ធផលល្អប្រសើរចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី និង ជាសហប្រធាន**

**គណៈកម្មាធិការជាតិវិនិយោគ**

ហត្ថលេខា ហត្ថលេខា

**គាត ឈន់ ហ៊ុន ម៉ាន**